# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់៤៩,២០០ដុល្លាអាមេរិក សម្រាប់គម្រោងសាងសង់ អគារពិសោធន៍វិទ្យាសាស្ត្រ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៤៩,២០០ដុល្លាអាមេរិកដល់សាលាគរុកោសល្យ និងវិក្រឹតការខេត្តពោធិ៍សាត់ សម្រាប់គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រក្នុងសាលាគរុកោសល្យ និងវិក្រឹតការខេត្តពោធិ៍សាត់។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក យ៉ូស៊ី ហ៊ីរ៉ូ ហ៊ីហ្គូជិ ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក ឈុន វណ្ណៈ នាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្តពោធិ៍សាត់នៅស្ថានទូតជប៉ុន។

ដើម្បីផ្តល់ការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រកាន់តែប្រសើរ សាលាគរុកោសល្យនិងវិក្រឹតការខេត្តពោធិ៍សាត់នឹងអនុវត្តគម្រោង សាងសង់អគារពិសោធន៍វិទ្យាសាស្ត្រ ដែលមានកម្ពស់មួយជាន់សម្រាប់គរុសិស្ស ប្រមាណ ១២០ នាក់ដែលនឹងក្លាយទៅជាគ្រូបង្រៀនកម្រិតបឋមសិក្សា ក្នុងខេត្តពោធិ៍សាត់ក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ សម្ភារៈសិក្សាដែលមានដូចជា តុពិសោធន៍ កៅអី និង ធ្នើសម្រាប់ដាក់សម្ភារៈពិសោធន៍ក៏នឹងត្រូវបានបំពាក់ផងដែរ។ យើងរំពឹងថាសិស្សានុសិស្សកម្រិតបឋមប្រមាណប្រាំពីរម៉ឺននាក់នៅក្នុងខេត្តនេះនឹងទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រកាន់តែប្រសើរពី លោកគ្រូ-អ្នកគ្រូ ដែលចេញពីសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។



កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការ ចិញ្ចឹមជីវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង ៤៨.៤ លានដុល្លាអាមេរិក

ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន  ៤៨៣ គម្រោង នៅទូទាំង ប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*